COMFREL NICFEC CHRAC Secretariat

# សេចក្ដីថ្លែងការណ៍រួម

# ស្ដីពី

# ការចាប់អារម្មណ៍ និងអនុសាសន៍ទៅលើដំណើរការសម្អាតបញ្ជីឈ្មោះអ្នកបោះឆ្នោត របស់សម្ព័ន្ធអង្គការសង្គមស៊ីវិល

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០០៧*

**សម្ព័ន្ធអង្គការសង្គមស៊ីវិល** សូមធ្វើការវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែង និងឆន្ទៈរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្នុងការសម្អាតបញ្ជីឈ្មោះអ្នកបោះឆ្នោត។ ប៉ុន្តែ**ការខិតខំ និងឆន្ទៈនេះអាចនឹងអស់តម្លៃ**ប្រសិនបើបញ្ជីឈ្មោះអ្នកបោះឆ្នោតមិនត្រូវបានធ្វើឱ្យមានភាពសុក្រឹត និងមិនទទួលការទុកចិត្តពីភាគីដែលពាក់ព័ន្ធ។

**សម្ព័ន្ធអង្គការសង្គមស៊ីវិល** យល់ឃើញថា សេចក្ដីណែនាំរបស់ គ.ជ.ប លេខ ៣៣២/០៧ ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០០៧ ស្ដីពី "ការស្រង់ឈ្មោះអ្នកបោះឆ្នោត ដែលត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៧ ដើម្បីបម្រើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០០៨" បានរៀបរាប់យ៉ាងលម្អិតអំពីការប្រគល់ភារកិច្ចទៅមន្ត្រីពាក់ព័ន្ធ ចូលរួមស្រង់ឈ្មោះអ្នកបោះឆ្នោត ដែលត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោតប្រចាំឆ្នាំ ប៉ុន្តែ "**ពុំបានរៀបរាប់អំពីដំណើរការ ឬនីតិវិធី**" ដែលស្របជាមួយនឹងវិធីសាស្ត្រថ្មីនោះទេ។ បើមើលទៅតាមភារកិច្ច យើងឃើញថា ស្មៀន និងមេឃុំ ចៅសង្កាត់ គឺជាមន្ត្រីគន្លឹះក្នុងការអនុវត្តន៏កិច្ចការនៃសេចក្ដីណែនាំចាស់ស្ដីពីការត្រួតពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០០៥។ ភារកិច្ចសំខាន់ថ្មីនោះ គឺការរៀបចំពិនិត្យ "**ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅសល់**" ធ្វើជាតម្រុយព័ត៌មានដំបូង ដើម្បីអនុវត្តសេចក្ដីណែនាំនេះ។ ក្នុងន័យនេះ សេចក្ដីណែនាំរបស់ គ.ជ.ប បានបកស្រាយថា "**ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅសល់**" ទាំងនោះ គឺជាមូលដ្ឋានព័ត៌មានដែលអាចរកឃើញទិន្នន័យនៃអ្នកបានស្លាប់ ផ្លាស់ប្ដូរទីលំនៅ គ្មានទីលំនៅក្នុងភូមិ ឬជាជនអន្តោប្រវេសន៏ ប៉ុន្តែ អ្នកសង្កេតការណ៏ជាច្រើនពន្យល់ថា មូលហេតុចំបងនៃការចែកប័ណ្ណព័ត៌មានដែលនៅសល់នេះ គឺមិនមែនតែការរកមិនឃើញប្រជាពលរដ្ឋទាំងនោះទេ ប៉ុន្តែអ្នកមានសិទ្ធិបោះឆ្នោតមួយចំនួនណានោះក៏មិនទទួលបានប័ណ្ណព័ត៌មានដែរ ដោយសារការរើសអើងខាងនយោបាយរបស់ "មេភូមិ" និងការអនុវត្តន៏ភារកិច្ចមិនមានប្រសិទ្ធភាព ខ្វះខាតថវិកាលើកទឹកចិត្ត។

**សម្ព័ន្ធអង្គការសង្គមស៊ីវិល** សូមផ្ដល់ការចាប់អារម្មណ៏ និងស្នើនូវអនុសាសន៏មួយចំនួនដូចតទៅ :

១. គ.ជ.ប គួរប្រើប្រាស់ "**បញ្ជីអ្នកបោះឆ្នោតដែលបានប្រើក្នុងការិយាល័យបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ២០០៧**" ជាមូលដ្ឋានរួមជាមួយប័ណ្ណព័ត៌មាននៅសល់ ដើម្បីអនុវត្តសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាព ពីព្រោះបញ្ជីនេះអាចឱ្យយើងរកឃើញ "**អ្នកមិនបានបោះឆ្នោត**" ហើយយើងអាចសិក្សាស្រាវជ្រាវយ៉ាងមានប្រសិទ្ធភាពអំពីបញ្ហាឈ្មោះអ្នក "ស្លាប់

ផ្លាស់ប្តូរទីលំនៅ ឬគ្មានទីលំនៅក្នុងភូមិ" ។ ចំពោះការបកស្រាយថា គ.ជ.ប មិនមានសិទ្ធិ ឬច្បាប់ហាមឃាត់ក្នុងការបើកយកបញ្ជីអ្នកបោះឆ្នោតដែលបានបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០០៧ ពីក្នុងកញ្ចប់សុវត្ថិភាពនោះ **សម្ព័ន្ធអង្គការសង្គមស៊ីវិល** បានពិនិត្យលើផ្លូវច្បាប់ និងបទបញ្ជា នីតិវិធីរបស់ គ.ជ.ប មិនមានមាត្រាណាមួយហាមមិនឱ្យយកបញ្ជីនេះ មកប្រើក្រោយពេលបោះឆ្នោតចប់សព្វគ្រប់ទេ។ ជាងនេះទៅទៀត ទោះជានៅពេលដែលបើកកញ្ចប់សុវត្ថិ-ភាពនេះ ឃើញមាននូវភាពមិនប្រក្រតីណាមួយ ក៏គ្មានជនណាមានសិទ្ធិក្នុងការប្តឹងអំពីលទ្ធផលនៃការបោះឆ្នោតបានដែរ ពីព្រោះផុតអាជ្ញាយុកាលបណ្តឹង។ ម្យ៉ាងទៀត គជប បានលើកយកហេតុផលថា មិនមានពេលវេលា និងថវិកាក្នុងការរើយកបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ ២០០៧ ចេញពីកញ្ចប់សុវត្ថិភាពបានទេ ហើយវាអាចប៉ះពាល់ដល់សុវត្ថិភាព/ភាពសម្ងាត់របស់អ្នកបោះឆ្នោត ប៉ុន្តែ **សម្ព័ន្ធអង្គការសង្គមស៊ីវិល** គិតថា នោះមិនមែនជាហេតុផល និងបញ្ហាលំបាកដែលមិនអាចដោះស្រាយបានទេ។ **សម្ព័ន្ធអង្គការសង្គមស៊ីវិល** សូមអំពាវនាវដល់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សហគមន៍ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលឱ្យចូលរួមគាំទ្រការងារដ៏មានសារៈសំខាន់នេះ។

២. ដើម្បីអនុវត្តភារកិច្ច របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដូចមានចែងក្នុងសេចក្តីណែនាំនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់តាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ២រូប ពីគណបក្សផ្សេងគ្នា ប្រសិនក្នុងករណីឃុំ សង្កាត់ នោះមានសមាជិកក្រុមប្រឹក្សាលើសពីពីរគណបក្ស។ ហើយសមាជិកក្រុមប្រឹក្សាទាំងពីររូបនោះ មិនមែនចេញមកពីគណបក្សរបស់មេឃុំ ចៅសង្កាត់។ មេឃុំ ចៅសង្កាត់ត្រូវមានតួនាទីត្រួតពិនិត្យ ចុងក្រោយលើបញ្ជីដែលបានសម្អាត។ ក្នុងករណីឃុំ